សារព័ត៌មាន ខ្មែរផុស ស.រ.អ
Free
KhmerPost USA
FREE BIWEEKLY CAMBODIAN ENGLISH NEWSPAPER SINCE 2007
978-677-7163 • VISIT KHMERPOST.US




**ព័ត៌មានសំខាន់ៗខាងក្នុង...**

**សមាគមខ្មែរប្រ៊ូវីដិនត្រៀមខ្លួន ធ្វើបុណ្យចូលឆ្នាំខ្មែរ**

*សូមអានទៅទំព័រទី ០២*



**ថាយ ជុន នឹងឈរជាបេក្ខជនក្រុមប្រឹក្សាក្រុងឡូវែលឆ្នាំ២០១៩**

*សូមអានទៅទំព័រទី ០៥*



**“វើតូ”របស់ ឌុណាល ត្រម**

*សូមអានទៅទំព័រទី ០៦*



**អនុវត្តច្បាប់អន្តោប្រវេសន៍នាំមកនូវការភ័យខ្លាច...**

*សូមអានទៅទំព័រទី ០៩*



# ពិធីទទួលលោក សម រង្ស៊ី នៅឡូវែល




ដោយ ពិន សំខុន

លោក សម រង្ស៊ី បានក្លាយជាប្រធានស្តីទីនៃគណបក្សសង្គ្រោះជាតិ លោកស្រី មូរ សុខហួរ និងលោក អេង ឆាយអៀង ជាតារាពរូប ដែលក្រុមរៀបចំទទួលបដិសណ្ឋារកិច្ចនៅឡូវែល

**តទៅទំព័រទី ០៧**

# Renaming of Park on Branch Street to Pailin Park

By Soben Pin

Lowell, Massachusetts — Lowell city council Rodney Elliott filed a motion on February 5, 2019 requesting Parks & Recreation Subcommittee meet and discuss renaming the park on Branch Street to Palin Park. The council unanimously referred the motion to the subcommittee.

*Please see **Renaming of Park**/02*



Lowell City Council Meeting Tuesday, March 19, 2019




# Colonel James M. Manni Sworn in as 14th Superintendent of the Rhode Island State Police

By KhmerPost USA

Providence, Rhode Island - Colonel James M. Manni was sworn by Governor Gina M. Raimondo earlier this month as the 14th Superintendent of the Rhode Island State Police.

“It is truly an honor and a privilege to be chosen as your Superintendent,” Colonel Manni said. “My goal is to serve with courage, commitment, integrity and respect, always striving to attain the exceptional levels of public service provided by each of the 13 men and women who have served in this role before me.”

*Please see **Colonel Manni**/03*



Courtesy photo: Colonel Manni speaks after having sworn in by Governor Gina M. Raimondo during a formal ceremony at the Rhode Island State House on March 1, 2019.

# Renaming of Park on Branch Street to Pailin Park

*Renaming of Park/From Front Page*

The subcommittee met and decided to support the renaming of the park at the city council meet-ing on Tuesday March 19. The council referred the motion to the Board of Parks and the final vote would take place sometimes before April. With the annual Cambodian New Year celebra-tion taking place at the park this year on April 20th, Lowell's Cambodian community may have an opportunity to celebrate the new year with the new pride having a park named after a popular cultural hub just across from the street - the Pailin Plaza which was established in the 1990s.

The Roberto Clemente Park used to be a baseball field where the Latino community gathered in the 1970s before the influx of the Cambodian refugees arrived. Prior to that, the park was named Washington Park and the name was changed to Roberto Clemente Park in the 1973 to honor a Puerto Rican native professional baseball player who died in a plane crash during a humanitarian trip to Latin America.

"Time has changed in many parts of Lowell. In the last 30 years, Clemente Park is mainly a gathering place for the Cambodian community for sports, cultural celebrations, family and kids' playground. It would give the community a sense of pride by having its name change to Pailin Park" said Councilor Elliott.

The motion was originally filed last year by Councilor Elliot along with Councilor Nuon but faced some heat by fellow council member Rita Mercier who spoke against it that it was also a pride for Latino community to have it named after its iconic baseball player. However, Councilor Elliott argued the Latino community is no longer using the park. Furthermore, the Little League baseball team of the Latino community has its own dedicated field as Roberto Clemente field behind the Bartlett Middle School two years ago which he is proud to have worked with the city to have it done. "Everyone is happy. That's the way I see it" said Councilor Elliott.

This week the discussion on renaming the park to Pailin Park has resurfaced. With the support of the community, the motion was passed and referred to Board of Parks 9-0, it is likely the park will be renamed. The next Board of Parks meeting is scheduled to be held on Wednesday March 27th at 6:00pm, Lowell City Hall. Public is welcome to attend.



KP USA File Photo: Cambodian traditional game "Tugs of War" was being played at the Clemente Park during a Cambodian New Year celebration in April 2016.




KP USA Photo: Pailin Plaza on Middlesex Street across from the Clemente Park




# សមាគមខ្មែរប្រូវីដិនត្រៀមខ្លួនធ្វើបុណ្យចូលឆ្នាំខ្មែរ

**តពីលេខមុន**

ដោយ ពិន សំខុន

សមាគមខ្មែរសម្បូរដោយអ្នកស្ម័គ្រចិត្តមកបង្ហាត់បង្រៀនភាសាខ្មែរ តែនៅមិនបានទៀងទាត់ទេ ផ្ទុយទៅវិញ គ្រូបង្ហាត់បង្រៀនរបាំជាវប្បធម៌ខ្មែរវិញ នៅបន្តសកម្មភាពយ៉ាងព្យាយាម។ នៅថ្ងៃចូលឆ្នាំខ្មែរខាងមុខ អ្នកគ្រូ ពៅ ធួង នឹងលោកគ្រូ ព្រាប រួន ដែលបង្ហាត់កុមារាកុមារី ក្នុងសមាគម មានមោទនភាពណាស់នឹងបង្ហាញទស្សនីយភាពដ៏ស្រស់បំព្រង នៃរបាំខ្មែរ ដែលអ្នកទាំងពីរដុតដៃដុតជើងរៀបចំ ឱ្យកើតបានវេទិការដែលមហាជនរង់ចាំមើលឆាកសិល្បៈខ្មែរ ដែលមិនព្រមសាបសូន្យ ទោះជានៅឆ្ងាយពីមាតុភូមិរាប់ពាន់យោជក៏ដោយក្តី។

នៅសាលដ៏តូចចង្អៀត ដែលគេទើបនឹងប្រជុំរួចភ្លាមនោះ ពួកគេមិនបានចង្អៀតចិត្តនឹងវ៉ាតទី រុញតុ រុញកៅអីចេញ ដើម្បីធ្វើឱ្យក្លាយទៅជាសាលហាត់របាំដ៏ធំទូលាយសម្រាប់កុមារៗមកហាត់សម្តែងរបាំរបស់ខ្លួន នាពេលបន្ទាប់ភ្លាមនោះទេ។ កុមារាកុមារីជាថ្នាលសិល្បករខ្មែរ បានត្រូវមាតាបីតានាំមកឱ្យហាត់រៀនរបាំជាវប្បធម៌ដូនតារបស់ខ្លួន ឱ្យនៅតែជាមរតកប្រចាំជាតិខ្មែរ ជំនួសឱ្យអ្នកដែលរវល់ខ្លាំងមិនបាននាំកូនចៅមកហាត់រៀន។

**ជីវភាពអ្នកប្រូវិដិន**

ទីនោះហៅថាតំបន់"គ្រេងស្តុន-Cranston" នៃក្រុងប្រូវិដិនរបស់រដ្ឋ"រ៉ូដអៃឡិន្ត" ខ្មែរយើងជាច្រើនបានទៅពូនគ្នារស់ជាសហគមន៍ដ៏ធំបង្គួរមួយ បន្ទាប់ពីឡូវែល មានហាងឧបភោគបរិភោគអាស៊ីធំ៧៥-៦សម្រាប់រកទទួលទាននៅទីនោះ នឹងតំបន់ជុំវិញ ហើយក៏មានវត្តអារាមចំនួន៣នៅបំរើសាសនាបូរុមបូរាណរបស់ពលរដ្ឋ មានវត្តសំខាន់ៗដូចជាវត្ត"ធម្មិការាម" នឹងវត្ត"ពុទ្ធមណ្ឌល"ជាដើម ដូច្នេះគឺជាទីប្រមូលផ្តុំប្រជាពលរដ្ឋមានសញ្ជាតិនឹងវប្បធម៌ដូចគ្នាបានយ៉ាងពេញមុខនឹងសុខសាន្ត លើសពីនេះទៅទៀតនោះ ប្រូវិដិនសម្បូរកាងារធ្វើសម្រាប់អ្នកសុខភាពមាំមួន រីឯអ្នកមិនសូវមាំមួនក៏មានកម្មវិធីជំនួយសុខភាព ធ្វើឱ្យប្រូវីដិនក្លាយជា តំបន់ងាយស្រួលរស់នៅជួបជុំគ្រួសារផង។




ខុសពីពេលមុន ដែល"គ្រេងស្តុន"នេះប្រកបដោយអសន្តិសុខ ពីព្រោះសម្បូរទៅដោយក្រុម"ជនពាល"ដែលតែងតែចល័តឆ្លាត់ឆ្វែង រត់គេចពីប៉ូលិសពីតំបន់មួយទៅមួយទៀត មកលួចរស់នៅប្រូវីដិននោះ... ឥឡូវបានស្ងប់ច្រើនហើយ ដោយការសំអាតរបស់ក្រុងសង្កាត់ ដោយក្រុមអាជ្ញាធររបស់អាមេរិកាំងចេះតែខ្លាំងក្លាទៅ គណកម្មការៗ មិនឈប់ឈរ នឹងដោយសារសន្លឹកឆ្នោត ដែលចេះតែសម្រាំងមនុស្សស្មោះត្រង់មកបំរើពលរដ្ឋ ក៏មិនឈប់ឈរដូចគ្នា, យ៉ាងនេះបានធ្វើឱ្យកូនចៅខ្មែរអាចទៅរៀនសូត្របានប្រសើរ ដំណែកឯឳពុកម្តាយ ក៏ប្រកបមុខរបរបានគ្រាន់បើ ដោយមិនមានការភ័យខ្លាចនឹងការគម្រៀមធ្វើបាបតាមផ្លូវ-នៅសាលាឬនៅផ្ទះ។




**សាររបស់សមាគមខ្មែរ**

តទៅទំព័រទី ១៤

# Colonel James M. Manni Sworn in as 14th Superintendent of the Rhode Island State Police

*Colonel Manni/From Front Page*

Colonel Manni formerly worked as the Rhode Island State Police trooper for 25 years and retired from the state police in 2015 as Major— the fifth highest-ranking member of the command staff.

He was then appointed as Director of Operations, Safety and Security for the Rhode Island Turnpike and Bridge Authority before being selected as Town Manager for the Town of Narragansett in 2016. On December 27, 2018, Governor Raimondo named him to succeed Colonel Ann C. Assumpico, who announced her retirement from the post in January 2019.

Retired Rhode Island State Police Colonel Brendan P. Doherty served as the emcee for the event. Five retired superintendents were in attendance, including Colonel Assumpico, Colonel Steven G. O'Donnell, Colonel Steven M. Pare and Colonel Edmond S. Culhane Jr., who collectively led the agency over the past 30 years.

Colonel Manni's wife, Tracey, and daughter, Olivia, sat with him during the ceremony, with other family members, friends and supporters.

"I am deeply committed to ensuring that every trooper, every barracks and every unit within this agency is properly trained, equipped and prepared to provide an unparalleled level of public service and protection to the citizens of Rhode Island," Colonel Manni said.

Congressman David M. Cicilline and Congressman James Langevin were among the many federal, state and local officials who attended, along with some top law enforcement officers from New England, including Massachusetts State Police Colonel Kerry Gilpin and Connecticut State Police Colonel Stavros Mellekas, as well as other members of their command staffs and a lieutenant from the New York State Police.



*Courtesy Photo: Six Rhode Island State Police superintendents who have served for the past 30 years: (l-r) Col. Steven O'Donnell; Col. Edmond Culhane; Col. Steven Pare (now Providence Public Safety Commissioner); Col. James Manni; Col. Brendan Doherty; and Col. Ann Assumpico.*

**DEPUTY SHERIFF**

The Rhode Island Department of Public Safety, Division of Sheriffs, is now recruiting qualified, motivated individuals who are seeking full-time employment as a Deputy Sheriff.

DEPUTY SHERIFFS perform courtroom security, inmate and prisoner transportation, extraditions and the execution of court documents.

Applications are being accepted through: **April 28, 2019**

For more information visit: WWW.SHERIFFS.RI.GOV

The State of Rhode Island, Department of Public Safety, is an Equal Opportunity and Diversity Employer.

To Apply Visit www.apply.ri.gov

**Explore Spring in the Greater Merrimack Valley**

Just a half-hour drive northwest of Boston lies the Greater Merrimack Valley. The changing seasons add to the vibrancy of the region.

There is an undeniable spirit in the Greater Merrimack Valley – the same spirit that gave birth to our country. Each of our 21 towns and cities has its unique charm and itinerary you need, your next adventure awaits you here.


















Greater Merrimack Valley Convention & Visitors Bureau adventuresawait merrimackvalley.org

MASSACHUSETTS massvacation.com

merrimackvalley.org

Follow us on Twitter and Instagram @MerrimackValley

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

AccuCare
Home Care Agency
Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារ៉ាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**
- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មាសហែលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**
- ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក២៤ម៉ោង

**To be eligibled for GAFC you must:**
- live in subsidized or public housing
- age 22 years and older
- eligible for Masshealth Standard

**Benefits you will get:**
- personal care service in your home,
- Medication Managemant
- an individual care plan developed by a registered nurse and case manager
- ongoing monitoring of needs
- 24-hour access to services

## ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# ថាយ ជុន នឹងឈរជាបេក្ខជនក្រុមប្រឹក្សាក្រុងឡូវែលឆ្នាំ២០១៩

ដោយ ពិន សំខុន

បេក្ខជនថ្មីទើបនឹងប្រកាសខ្លួន កាលពីថ្ងៃទី១៦មិនានេះ ថានឹងឈរជាបេក្ខជនក្រុមប្រឹក្សាក្រុងឡូវែល នាឆ្នាំ២០១៩នេះ គឺលោក ថាយ ជុន - Ty Chun អាយុ៣៩ឆ្នាំ មានកិរិតវិជ្ជាបរិញ្ញាប័ត្រខាងគ្រប់គ្រងមានបទពិសោធន៏ច្រើន ដោយធ្លាប់ធ្វើបុគ្គលិកសន្តិសុខ ក៏ដូចជាបុគ្គលិកខាងថែរសុខភាព ហើយឥឡូវមានបើកហាងមួយសម្រាប់ជួយចាស់ៗឱ្យមានការធានារ៉ាប់រងសុខភាពដោយមិនយកថ្លៃ លោកមានភរិយា នឹងកូន២នាក់ ។

ឡូវែលជាតំបន់ដ៏សម្បូរពលរដ្ឋដើមកំណើតខ្មែររស់នៅ ហើយក៏មានតំណាងជាតិខ្មែរ ជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាក្រុងបាន២រូប (ដែលមាន១រូបបានកាន់ដំណែងជាអភិបាលក្រុងរងសព្វថ្ងៃផង) -ជាគណកម្មការសាលារៀនមួយរូប-នឹងជាដំណាងរដ្ឋមួយរូប ។ តែបេក្ខជនក្មេងៗមានសមត្ថភាពគ្រប់គ្រាន់ ដែលគេហៅថា "ឈាមថ្មី"នៅមិនមានទេ, លោក ថាយ ជុន អាចថាជាមនុស្ស"ជំនាន់ថ្មី"ដែលផ្តើមហ៊ានចូលប្រឡូក ក្នុងឆាកនយោបាយក្នុងនាមជាខ្មែរ-អាមេរិកាំងនោះហើយ ។



នៅពេលសួរថា"ហេតុអ្វីបានជាលោកចង់ឈរជាបេក្ខជនក្រុមប្រឹក្សាក្រុងនៅពេលនេះ?" លោក ថាយ ជុន ឆ្លើយថា "ខ្ញុំឃើញថា ឡូវែលជាកន្លែងគួរឱ្យចង់រស់នៅណាស់ តែនៅមានបញ្ហាមួយចំនួននៅឡើយ ដែលត្រូវតែមានអ្នកដោះស្រាយ ដើម្បីអនុញ្ញាត្តិឱ្យមនុស្សដូចជាកូនខ្ញុំជាដើមរួមនឹងកូនអ្នកឯទៀត អាចរស់នៅរីតតែប្រសើរជាងនេះ មានតម្លាភាព មានភាពយោគយល់គ្នារវាងសហគមន៏យើងមួយនឹងសហគមន៏មួយទៀត ។

លោក ថាយ ជុន បានបង្ហាញនូវការគាំទ្រដល់ភាពជា"ដំណាងនៅតាមតំបន់-Diversity" ស្របតាមអត្ថន័យនៃរដ្ឋធម្មនុញ្ញ ដែលបណ្តាលឱ្យមានការប្តឹងផ្តល់រឿងឡើងតុលាការរបស់សាលាក្រុងឡូវែល ហើយតំបន់នីមួយៗអាចមានតំណាងរបស់សង្កាត់ខ្លួន។ លោក ថាយ ជុន មានការស្រម័យថា លោកអាចចូលរួមកសាងឡូវែល ដោយសារការចូលចិត្តជួយឈឺឆ្អាលសហគមន៏ស្ម័គ្រចិត្តបំរើអង្គការមនុស្សធមិសុខភាពមនុស្សគ្រប់រូបឱ្យបានថ្កុំផ្កើងរុងរឿងនេះ ក៏ដោយសារលោក ជុន នៅចងចាំថាខ្លួនជា អតីតជនភៀសខ្លួន ដែលមករស់នៅសហរដ្ឋអាមេរិក នាឆ្នាំ១៩៩០ ក្រោមតំបូលផ្ទះនៃអ្នកមានប្រាក់ចំណូលតិចតួចប្រមាណ២០ឆ្នាំ ធាត់ធំរៀនសូត្រនៅឡូវែលជារៀងរហូតមក មិនអាចឱ្យលោកបំភ្លេចជីវភាពនេះបានឡើយ ។



ថាយ ជុន

លោក ថាយ ជុន នឹងរៀបចំពិធីធ្វើការរកកំរៃធ្វើការឃោសនា នៅថ្ងៃទី២៣ មេសា ២០១៩ នៅភោជនីយដ្ឋានសានីដា ហើយលោក ជុន សូមអញ្ជើញបងប្អូន មេត្តាជួយគាំទ្របេក្ខភាពដ៏ក្មេងខ្ចីនេះឱ្យបានកុះករផង ។






(ព័តិមានអន្តរជាតិ)

# "វ៉េតូ" របស់ ឌុណល ត្រម

ដោយ ពិន សំខុន

"វ៉េតូ"គឺជាដាវអដ្ឋាសឹករបស់ប្រធានាធិបតីអាមេរិកាំងសម្រាប់ប្រឆាំងនឹងការសម្រេចចិត្តរបស់ព្រឹទ្ធសភា ដែលជាស្ថាប័នកំពូលរបស់ប្រទេស។ លោកប្រធានាធិបតី ឌុណល ត្រម មានបំណងសង់"ជញ្ជាំងអន្តោប្រវេសន៏"នាព្រំប្រទល់ដែនម៉ិកស៊ិក លោកបានបង្ករព្រឹត្តិការ"ប្រកាសភាពអាសន្ន"នៅភូមិភាគខាងត្បូង ដើម្បីរកថវិការ៨ពាន់លានដុល្លាសម្រាប់សំណង់នោះ, ប៉ុន្តែកាលពីថ្ងៃព្រហស្បតិ៍ទី១៤មិនាកន្លងទៅ ព្រឹទ្ធសភាអាមេរិកាំង បានសម្រេចដោយសន្លឹកឆ្នោត៥៩-៤១(មានសមាជិកសភា១២រូប ខាងគណបក្សសាធារណរដ្ឋមិនបានបោះឆ្នោតស្របតាមបំណងប្រធានាធិបតីទេ) គឺមិនអនុញ្ញាតិឱ្យប្រធានាធិបតីប្រើយន្តការ"ប្រកាសភាពអាសន្ន"បានទេ, ហេតុនេះហើយ ដោយទាល់ច្រក លោក ត្រម បានសម្រេចប្រកាសថាលោកនឹងប្រើ"វេតូ" គឺប្រើដាវអាដ្ឋាសឹកសម្រាប់រំលងអដ្ឋារបស់សភា ដើម្បីយកថវិការនោះមកប្រើ ដើម្បីសម្រេចបំណងរបស់លោក។ នេះគឺជាលើកទី១ហើយដែលតាំងពីជាង៤០ឆ្នាំមកហើយ ដែលមិនមានប្រធានាធិបតីណាប្រើ"វ៉េតូ"នេះ រំលងព្រឹទ្ធសភានោះទេ។

ស្របពេលជាមួយគ្នានោះ គណកម្មការសភាបានកោះហៅប្រធានគណកម្មការឃោសនារបស់ ឌុណល ត្រម មកសួរចម្លើយ គឺលោក...។ នៅចុងបញ្ចប់បុរសនោះបានទទួលទណ្ឌកម្មជាប់គុក៧ឆ្នាំកន្លះពីបទពុករលួយនឹងបានឆ្លើយភូតភរសភាជាតិ។ មនុស្សសំខាន់ៗ ជុំវិញលោក ឌុណល ត្រម កំពុងជាប់គុកជាបន្តបន្ទាប់ សភាជាតិនឹងក្រុមរដ្ឋអាជ្ញាបានសម្រេចធ្វើការស៊ើបអង្កេតលើអង្គការនឹងមូលនិធិទាំងអស់របស់លោក ឌុណល ត្រម ដែលគេសង្ស័យថា "មានអំពើពុករលួយ"។

ស្ថានភាពនយោបាយតឹងតែងសម្រាប់ ឌុណល ត្រម តែអ្នកស្រី ប៉ូឡូស៊ី ប្រធានខាងបក្សប្រឆាំង មិនបានប្រឹងប្រែងក្នុងការ"ទាញទម្លាក់លោកប្រធានាធិបតីមុនអាណត្តិ -Empeachment"នោះទេ -ក៏ប៉ុន្តែបណ្តាញស៊ើបអង្កេតនៃតុលាការកំពុងតែតាមដានទម្លាយរឿងអាថិកំបាំងរបស់ ឌុណល ត្រម កាន់តែកៀកកិតណាស់ហើយ បន្ទាប់ពីមនុស្សជំនិតៗ បានសារភាពថា "លោក ត្រម បានដឹងនឹងបញ្ជាអំពើឧក្រឹដ្ឋមួយចំនួននៅសេដ្ឋវិមាន"រួចមក។






លោកប្រធានាធិបតី ឌុណល ត្រម ចុះហត្ថលេខាលើ"វ៉េតូ"

ក្រុមហ៊ុនអចលនៈទ្រព្យ អឺប៊ឺន រាលអ៊ីស្តេត
URBAN REAL ESTATE
មជ្ឈមណ្ឌលផ្តល់សេវាជួលលំនៅដ្ឋាន
Residential Leasing Center

ដាញ៉េល តាន
ភ្នាក់ងារអចលនៈទ្រព្យ
Daniel Tan
Real Estate Agent
Cell: 978-902-6354
508 Westford Street • Lowell, MA 01851
(978) 454-0444

ក្រុមហ៊ុនធានារ៉ាប់រ៉ង ឃេឃេ អ៊ីនសួរិន អេជេនស៊ី
KK Insurance Agency, Inc.
រថយន្ត • លំនៅដ្ឋាន • អាជីវកម្ម
Car • Home • Business
508 Westford Street
Lowell, MA 01851
978-970-2212
kk@kkinsurancema.com


LEGEND
MOTOR GROUP, INC.
ហាងជួលជុលរថយន្ត លេជេន
មានសេវាជួលជុលរថយន្តគ្រប់ប្រភេទ
រយន្ត ប៉ះ បុក ខូចខាត និងក្រពិតមែន រឺទេ ?
ទូរស័ព្ទ 978-458-2085
COLLISION REPAIR
BEEN IN AN ACCIDENT?
FROM DENTS TO TOTALED,
WE CAN FIX IT ALL.

យើងរៀបចំសណ្តោងរថយន្ត នៅពេលត្រូវការ, ធ្វើការជាមួយនឹងក្រុមហ៊ុនធានារ៉ាប់រងរបស់លោកអ្នកនិងរៀបចំរាល់ឯកសារទាំងអស់។
ការពេញចិត្តរបស់លោកអ្នក គឺជាអាជីវកម្មរបស់យើង។
115 Rock St. Unt #7 Lowell, MA 01854

តមកពីទំព័រទី ០១

# ពិធីទទួលលោក សម រង្ស៊ី នៅឡូវែល

បានទទួលស្វាគមន៍យ៉ាងអ៊ូអរនៅភោជនីយដ្ឋាន"សំពៅមាស"កាលពីថ្ងៃទី១៧មិនា២០១៩ វេលាម៉ោង៧ល្ងាច រង់ចាំដោយភ្ញៀវភាគច្រើនមកពីតំបន់ឆ្ងាយៗនឹងភ្ញៀវក្នុងស្រុកទាំងអស់ប្រមាណជា២០០នាក់។

កម្មវិធីបានចាប់ផ្តើមនៅម៉ោង៩យប់ ដោយមានពរជយ័ន្តោពីព្រះសង្ឃ ជូនដល់ថ្នាក់ ដឹកនាំបន្ទាប់មកមានសេចក្តីរាយការពីលោកស្រី មូរ សុខហួរ ពីកិច្ចប្រជុំថា"មានការបើកកិច្ចប្រជុំគណអចន្ត្រៃយ៍របស់គណបក្សចំនួន២ថ្ងៃនៅឡូវែលនេះមុនពេលមកដល់រាត្រីជុបលៀងចុងក្រោយនេះ"។ គេអាចដឹងបានថា ពីកិច្ចប្រជុំ២ថ្ងៃនោះ គណកម្មការបានបញ្ចេញ សេចក្តីថ្លែង-ការមួយក្នុងនាម គណបក្សសង្គ្រោះជាតិ និយាយពីការតស៊ូបន្តរទៅទៀតរបស់គណបក្សសង្គ្រោះជាតិ ដើម្បីឱ្យមានការដោះលែងលោក កឹម សុខា ជាប្រធានគណបក្ស នឹងបង្ហាញពីភាពខុសច្បាប់នឹងអំណាចផ្តាច់ការនៃការគ្រប់គ្រងសព្វថ្ងៃរបស់មនុស្សតែម្នាក់ក្នុងគ្រួសារតែមួយនៅកម្ពុជា ហើយទាមទារឱ្យមានការបោះឆ្នោតសារជាថ្មីនៅកម្ពុជាផង"។ នារាត្រីនោះដែរ លោក ស្រី មូរ សុខហួរ បានលាតត្រដាងពីគណកម្មការពិសេសមួយសម្រាប់រៀបចំដំណើរចូលនិវត្តន៍ត្រឡប់ទៅមាតុភូមិវិញ ដែលលោក សម រង្ស៊ី បានប្រកាសជាច្រើនដងហើយ តែធ្វើមិនដែលបានសម្រេច បណ្តាលឱ្យមានការទិទានយ៉ាងច្រើន គឺដំណើររបស់ប្រធានស្តីទីម្នាក់នេះ ត្រូវដាក់បន្ទុកទៅឱ្យគណកម្មការថ្មីមួយនោះ ជាអ្នករៀបចំមាតុភូមិនិវត្តន៍របស់ សម រង្ស៊ី ឱ្យបានមុនដំណាចឆ្នាំ ២០១៩នេះ (តំណាងម្នាក់បានផ្សព្វផ្សាយថា ប្រាក់៣០ម៉ឺន ដែលលោក សម រង្ស៊ី ត្រូវការ សម្រាប់ដំណើរមាតុភូមិនិវត្តន៍ នោះរកបានគ្រប់គ្រាន់ហើយ"។



លោក រ៉ុង ឈុន

លោក រ៉ុង ឈុន អតីតប្រធានសហជីពនឹងជាអតីតសមាជិកគ.ជ.ប. ដែលជាតារាឯកម្នាក់ក្នុងចំណោមអ្នកតស៊ូនយោបាយដ៏ល្បីល្បាញណាស់ដែរ បានមកដល់ក្រុងឡូវែល នារាត្រីនោះ តែមកគ្រាន់តែជាភ្ញៀវម្នាក់តែប៉ុណ្ណោះ លោកបានថ្លែងយ៉ាងខ្លីថា លោកមកសហរដ្ឋនេះក្នុងដំណើរផ្លូវ ការមួយតែលោកឆ្លៀតមកជួបបងប្អូនខ្មែរ គ្រាន់សំណេះសំណាលឱ្យបានដឹងពីស្ថានភាពខ្លះនៃប្រជាពលរដ្ឋ-កម្មករនឹងគ្រូបង្រៀនយើងឱ្យដឹងថា សិទ្ធមនុស្សនឹងប្រជាធិបតេយ្យនៃប្រទេសយើង គឺបានដើរត្រឡប់ថយក្រោយទៅវិញហើយ ហើយលោកក៏មិនបាននិយាយពីបុព្វហេតុដែលលាចាកចេញពីគ.ជ.ប.ដែរ ដោយមិនមានពេលគ្រប់គ្រាន់ ។

ដំណាក់ការថ្មី នារាត្រីទី១៧មិនានេះ បានបង្ហាញថា: ១-លោកសម រង្ស៊ីនឹងមន្ត្រីសង្គ្រោះជាតិដែលមកចូលរួមបានយកគណបក្សសង្គ្រោះជាតិ មកកាន់ឡើងវិញ ដែលកាលពីពេលមុនលោកបានទទួលស្គាល់ថា បានស្លាប់បាត់ទៅហើយ នៅពេលទៅបង្កើតបានជា"ចលនា ឬសមាគម"នានា... ២-លោកមានបំណងបង្រួបបង្រួមគណបក្សទាំងអស់ឱ្យប្រឆាំងជាមួយលោកដោយប្រើសម្ព័ន្ធភាពជាមួយលោក កឹម សុខា ដែលកំពុងជាប់ក្នុងការឃាត់ឃាំង គឺដើម្បីប្រឆាំង ដោយសន្តិវិធីនឹងរបបឯកបក្សនិយមភ្នំពេញ ៣-លោកពង្រឹងជំហ៊រនៅតែចង់ចូលទៅកម្ពុជាវិញ ដើម្បីទៅរំលំរបបលោក ហ៊ុន សែន ។

នៅឡូវែលប្រជាពលរដ្ឋភាគច្រើនសុទ្ធតែជាអ្នកគាំទ្រគណបក្សសង្គ្រោះជាតិតែពេលនេះមានការរារែកនឹងចូលរួម ក្នុងការតស៊ូជាមួយសង្គ្រោះជាតិមួយនេះសារជាថ្មី ពីព្រោះតែគេយល់ថា: ជាក្រុមបក្ខពួកនិយម - មានការសម្រេចចិត្តប្តូរផ្លាស់លឿនតាមមិនទាន់ - មិនដែលទទួលលទ្ធផលអ្វីពីការតស៊ូរបស់ក្រុមនេះទេ គឺតែងតែឱ្យហ៊ុនសែនឈ្នះជាដ៏រាប...គេគិតថា"បើនៅដេកផ្ទះវិញ មុខជានឹងឈ្នះឯង"ជាមិនខាន។


ការិយាល័យ មេធាវី
ថំមាស ស្តាលីយ៉ាណូស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com






# ជួបបញ្ហាបង់ថ្លៃកម្តៅ?

## កម្មវិធីជំនួយឥន្ធនៈអាចជួយអ្នកបាន!*

*អាចមានលក្ខខណ្ឌខ្លះ

រាល់ឆ្នាំអង្គការ Community Teamwork ផ្តល់ជំនួយឥន្ធនៈដល់១២,០០០លំនៅដ្ឋាន ដែលជួបបញ្ហា ដោយសារចំណាយច្រើនលើថ្លៃកម្តៅ

COMM
UNITY
TEAM
WORK





| ទំហំគ្រួសារ | ប្រាក់ចំណូល |
|---|---|
| 1 | $ 35,510 |
| 2 | $ 46,437 |
| 3 | $ 57,363 |
| 4 | $ 68,289 |
| 5 | $ 79,215 |
| 6 | $ 90,141 |

### សូមទាក់ទងដើម្បីណាត់ជួប

សូមទាក់ទងដើម្បីណាត់ជួប
ទូរស័ព្ទលេខ៖ ៩៧៨ ៤៥៩ ៦១៦១
អ៊ិនធើណិត៖ www.commteam.org
ចុចលើពាក្យ Fuel Assistance ពណ៌ខៀវ នៅលើគេ ខាងស្តាំដៃ

ការផ្សព្វផ្សាយនេះ គឺមានការជួយឧបត្ថម្ភពីកម្មវិធីជំនួយផ្នែកថាមពលសម្រាប់គ្រួសាមានចំណូលទាប តាមរយៈថវិការដែលបានមកពីក្រសួងអភិវឌ្ឍន៍សហគមន៍ និងលំនៅដ្ឋានម៉ាសាឈូសេត។

ជំនួយនេះផ្តល់តាមសហគមន៍ដូចខាងក្រោម

| | |
|---|---|
| Arlington | Groton |
| Bedford | Lexington |
| Belmont | Lowell |
| Billerica | Pepperell |
| Burlington | Tewksbury |
| Carlisle | Tyngsboro |
| Chelmsford | Waltham |
| Dracut | Watertown |
| Dunstable | Westford |

Wilmington

# ការអនុវត្តន៍ច្បាប់អន្តោប្រវេសន៍នាំមកនូវការភ័យខ្លាចដល់សហគមន៍ខ្មែរ

ដោយ សុបិន ពិន

សាន ហ្វានស៊ីស្កូ, រដ្ឋកាលីហ្វរនីញ៉ា "ពលរដ្ឋខ្មែរអាមេរិកកាំងទូទាំងសហរដ្ឋអាមេរិក កំពុងតែរស់នៅក្នុងភាពភ័យខ្លាចទៅនឹងការអនុវត្តន៍ច្បាប់អន្តោប្រវេសន៍យ៉ាងមុតមាំរបស់រដ្ឋាលលោកត្រាំ។ ភាគរយដ៏តិចតួចនៃជនភៀសខ្លួនខ្មែរដែលបានមកកាន់សហរដ្ឋអាមេរិកជាច្រើនឆ្នាំមកហើយ បានប្រព្រឹត្តបទល្មើសក្នុងប្រទេសនេះ។ ចំពោះបទល្មើសទាំងនេះ ពួកគេត្រូវបានចាប់ខ្លួន, កាត់ទោស ហើយមានករណីជាច្រើន-ពួកគេត្រូវបានប្រព្រឹត្តល្មើស និងបន្ទាប់មកកាត់ទោសឱ្យចាប់ពន្ធធនាគារ ឬការព្យួរទោស។

នៅពេលត្រូវបានផ្តន្ទាទោស ទីភ្នាក់ងារអាមេរិកទទួលបន្ទុកជនអន្តោប្រវេសន៍ និងពន្ធគយ ឬICE ចេញនូវសេចក្តីបង្គាប់បណ្តេញចេញដែលបានផ្តល់រដ្ឋាភិបាលអាមេរិកនូវសិទ្ធអំណាចក្នុងការបណ្តេញចេញបុគ្គលទាំងនេះពីសហរដ្ឋអាមេរិក ហើយបញ្ជូនត្រឡប់ទៅកាន់ប្រទេសកម្ពុជាវិញ។ មានប្រហែលជា៧00ករណី ពលរដ្ឋខ្មែរត្រូវបានបញ្ជូនទៅកាន់ប្រទេសកម្ពុជា ប៉ុន្តែមានករណីជាច្រើនទៀតប្រហែលជាង ១,៩00 ករណី រដ្ឋាភិបាលអាមេរិកមិនមានការចាត់វិធានការបន្ថែមនោះទេ។ ភាគច្រើននៃអ្នកដែលស្ថិតនៅក្នុងករណីមិនទាន់មានចំណាត់ការពីរដ្ឋាភិបាល បានកំពុងរស់នៅដោយសុខសាន្តនៅក្នុងសហគមន៍របស់ពួកគេ និងនៅតែមិនមានទោសពៃនោះទេ។



Protesters demand for the immigration rights in responding to ICE raids on Cambodian communities at a 2013 demonstration . Photo credit: 1LoveMovement

ទោះបីជាយ៉ាងណាក៏ដោយវិធានការថ្មីនៃការអនុវត្តន៍បទសេចក្តីបង្គាប់នៃការបណ្តេញចេញដែលត្រូវបានចេញជាច្រើនឆ្នាំមកហើយនោះ បានធ្វើឱ្យមានកំណើនក្តីបារម្ភណ៍ក្នុងសហគមន៍កម្ពុជាទូទាំងសហរដ្ឋអាមេរិក។ វាក៏បានធ្វើឱ្យពលរដ្ឋខ្មែរពីរនាក់ គឺណាក ហឹម ឈឿន និងម៉ូនី និត ធ្វើការប្តឹងទាស់នឹងរដ្ឋាភិបាលអា-មេរិកនៅតុលាការរដ្ឋការលីហ្វរញ៉ា។ ពួកគេបានអះអាងថា ទីភ្នាក់ងារអាមេរិកទទួលបន្ទុកជនអន្តោប្រវេសន៍និងពន្ធគយ កំពុងតែរំលោភសិទ្ធរបស់ពួកគេចំពោះនិតិវិធីដ៏ត្រឹមត្រូវនៃច្បាប់ក្រោមរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក ដោយធ្វើការវាយឆ្មក់ និងចាប់ពួកគេដាក់ពន្ធធនាគារដោយគ្មានឱកាស់សម្រាប់ធ្វើសវនាការទាល់តែសោះ។ (និតិវិធីដែលត្រឹមត្រូវ គឺថាអ្នកមានសិទ្ធក្នុងការបើកសវនាការដោយយុត្តិធមិ មុនពេលត្រូវបានដកហូតសិទ្ធិសេរីភាពរបស់អ្នក)។

លោក ឈឿន និងលោក និត ក៏បានស្នើរសុំតុលាការដើម្បីឱ្យចាត់ទុកករណីរបស់ពួកគេជាករណីប្តឹងតំណាង ដែលមានន័យថា សេចក្តីសម្រេចណាមួយដែលត្រូវបានចេញក្នុងករណីនេះនឹងត្រូវអនុវត្តន៍ចំពោះបុគ្គលគ្រប់រូបក្នុងសហរដ្ឋអាមេរិកដែលក្នុងនៅក្នុងស្ថានភាពដូចគ្នានេ។ តុលាការបានយល់ព្រមទទួលយកការស្នើសុំនេះ។ តុលាការក៏បានចេញនូវដីកាបណ្តោះអាសន្នដែលហាមឃាត់ ICE មិនឱ្យធ្វើការសកម្មភាពឆ្មក់ និងចាប់ខ្លួនមនុស្សដាក់ពន្ធធនាគារបន្ថែមណាមួយដោយគ្មានការផ្តល់លិខិតជូនដំណឹងដល់ពួកគេជាមុនរយះពេល១៤ថ្ងៃ ដើម្បីឱ្យពួកគេមានឧកាស់ក្នុងកាប្រមូលឯកសារសំខាន់ៗណាមួយដែលនឹងអាចឱ្យពួកគេការពារប្រឆាំងទល់នឹងលិខិតបង្គាប់បណ្តេញចេញនោះ។

កាលពីឆ្នាំ ២00២, សហរដ្ឋអាមេរិក និងកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមាតុភូមិនិវត្តន៍ដោយភាគីកម្ពុជាយល់ព្រមអនុញ្ញាតឱ្យមានការនិរទ្ទេសត្រឡបវិញមកកាន់កម្ពុជារាល់ពលរដ្ឋខ្មែរពីសំណាក់ភាគីសហរដ្ឋអាមេរិក។


San Francisco residents attended a forum to learn how to protect themselves from the immigration enforcement. Photo credit: Kevin Lo/PRI

ទោះបីជាយ៉ាងណាក៏ដោយទំនាស់ផ្ទៃកនយោបាយក្នុងប្រទេសកម្ពុជា បានឈានដល់ចំណុចកំពូល នៅពេលពេលដែរមេដឹកនាំគណបក្សសង្គ្រោះជាតិ គឹម សុខា ត្រូវបានចាប់ខ្លួននៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ ២០១៧ ពីបទក្បត់ជាតិ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចោទប្រកាន់មេដឹកនាំគណបក្សប្រឆាំងពីបទសមគំនិតជា

តទៅទំព័រទី ១២



# Boch Honda West

299 Littleton Rd, Westford, MA 01886
**EXIT 32 - OFF 495**

HOME OF THE 20 YEAR 200,000 MILE LIMITED POWERTRAIN ★ WARRANTY ★ BOCH

## ផ្តល់ជូនការធានា រយៈពេល 20 ឆ្នាំ/រយៈចំងាយ 200,000 ម៉ាយ

រួមបញ្ចូលរាល់ការទិញរថយន្តហុងដាសេរីថ្មីទាំងអស់!

លោកអ្នកអាចធ្វើដំណើរជុំវិញពិភពលោក 8 ដងហើយ នៅតែមានការការពារ!

# MARCH SALES DRIVE

Honda dream garage spring event



New 2019 Honda **CIVIC LX SEDAN**
តម្លៃជួល **$68**
ក្នុងមួយខែសម្រាប់ 24 ខែ



New 2019 Honda **ACCORD LX SEDAN**
តម្លៃជួល **$118**
ក្នុងមួយខែសម្រាប់ 24 ខែ



New 2019 Honda **CR-V LX AWD**
តម្លៃជួល **$148**
ក្នុងមួយខែសម្រាប់ 24 ខែ



New 2019 Honda **PILOT LX AWD**
តម្លៃជួល **$208**
ក្នុងមួយខែសម្រាប់ 24 ខែ

សម្រាប់ព័ត៌មានបន្ថែមពីរថយន្ត
សូមទំនាក់ទំនង ខេលី វីដាល: kvidal@bochhondawest.com

ត្រូវការបុគ្គលិកផ្នែកលក់!
ទំនាក់ទំនងមកកាន់ ខេវិន ក្រេក: kcregg@bochhondawest.com

**BochHondaWest.com | (978) 252-2125** HONDA




## ផ្តើមសេចក្តី

អារម្ភកថា

យើងសូមជូនរឿងថ្មីមួយទៀត គឺរឿង"កុមារ យោធិន្ទ"ជាប្រវត្តិកុមារប្រមាណជា១ពាន់នាក់ ដែលបានចូលទៅបំរើក្នុងកងទ័ពតាំងពិអាយុ១០ឆ្នាំ នៅសាលារៀនមួយដែលកងខេមរភូមិន្ទបាន បង្កើតឡើងបន្តពីអាណានិគមបារាំងក្នុងបំណងជួយចិញ្ចឹមកូនរបស់កងទ័ពបង្ហាត់បង្រៀនមុខវិជ្ជាដែល ឪពុករបស់គេស្រឡាញ់ចូលចិត្តនឹងបានបូជាជីវិត ដើម្បីមាតុភូមិរបស់គេថែមទៀត។

ជារឿងពិតរបស់យុវជនមួយក្រុមរស់នៅដាច់ពីការថ្នាក់ថ្នមរបស់ឪពុកម្តាយមិនដូចក្មេង ឯទៀត គេចិញ្ចឹមកុមារទាំងនោះ ក្រោមវិន័យតឹងរឹងនៃកងទ័ពបង្ហាត់ហ្វឹកហ្វឺននឹងរៀនសូត្រវិជ្ជា ចម្បាំងតាំងតែពីនៅតូច តែសាធារណជនមិនសូវដែលដឹងថា"សាលានោះជាអ្វី? បង្ហាត់បង្រៀន របៀបណា? នឹងស្គាល់ថា ជាអ្វីនោះទេ" ក្រៅតែពីអ្នកនៅក្នុងក្រុងជាមួយនឹងអ្នកមិនឆ្ងាយពីបន្ទាយ នៃកូនទាហ៊ានទាំងនោះ តែប៉ុណ្ណោះដែលស្គាល់ ហើយឱ្យឈ្មោះថា"ពួកក្មេងហ្វូង" ដែលជាឈ្មោះ បកប្រែពីពាក្យបារាំងមកថា"Les enfants de troupe"។

# ជីវភាពសិស្សសាលាកុមារយោធិន្ទ(ត)

### ភាគ១ - សាលាកងកុមារយោធិន្ទ

ពីវ័យ១០ឆ្នាំរហូតដល់១៨ឆ្នាំ មិនត្រឹមតែនៅឆ្ងាយពីការអប់រំរបស់ម្តាយឪពុកតែប៉ុណ្ណោះទេ ពួកគេមិនសូវមានទំនាក់ទំនងតាមការសរសេរសំបុត្រឬក៏ទូរស័ព្ទទៅមករកអ្នកមានគុណរបស់ខ្លួនតែម្តង កុមារយោធិន្ទ គឺជាក្រុមកុមារដែលបានបាត់បង់ការស្រឡាញ់ថ្នាក់ថ្នមទាំងស្រុងជាធម្មជាតិពីមានតាបិតារបស់ខ្លួន ហើយរស់តែជាមួយមេបញ្ជាការ ជាមួយតែឯកសណ្ឋានជាកងទ័ព ហើយនឹងបទបញ្ជាវិន័យតែប៉ុណ្ណោះ។ ក្រៅពីនោះ នៅមានសាលារៀនគ្រូបង្រៀនគ្រូបង្ហាត់ ដែលផ្តល់ឱ្យដោយរាជការខ្មែរ ក្នុងក្របខណ្ឌនៃជំនួយយោធាដល់យុទ្ធជននៃប្រទេសក្រីក្រ ឱ្យអាចកាពារប្រទេសទៅអនាគតរឹតតែប្រសើរបាន។

ម្ហូបអាហារសិស្សសាលាកុមារយោធិន្ទ

ឱកាសដែលកុមារយោធិន្ទម្នាក់ៗចងចាំជាងគេ គឺពេលបាយ ដែលចែកជា៣ពេលព្រឹកគឺស្រស់ស្រូប គេហៅថា "កាស់គ្រូត-Casse Croute"នៅម៉ោង៦ព្រឹក, អាហារពេលថ្ងៃត្រង់គេហៅថា "ដេហ្សឺណេ-Dejeuner"នៅម៉ោង១១កន្លះ, នឹងអាហារពេលល្ងាច គេហៅថា "ឌីណេ-Diner"នៅម៉ោង៥ល្ងាច គ្មានពេលបាយផ្សេងពីនេះទៀតទេ។

នៅពេលបាយម្តងៗ នាយករោងបាយ "សែពគូស៊ីន-Chef cuisine"តែងវាយជួង ហៅសិស្សឱ្យមកតម្រៀបជួរ តាមក្រុម មានឯកសណ្ឋានខ្លីបេរ៉េក្រហមម្នាក់ៗត្រូវមានមានចាន នឹងស្លាបព្រាសម មុននឹងអនុញ្ញាត្តិឱ្យចូលទៅ


ពិន សំផុន ប្រធានសិស្សកុមារយោធិន កំពង់ចាម

កាន់ស្តុករៀងៗខ្លួន, ១ស្តុកមាន៦នាក់ ។ ស្តុកនីមួយៗមានមុខម្ហូបជាទូទៅគឺៈ មានបាយរួមមួយចានដែកធំ សម្លរទឹករួមមួយចានដែកប៉ុនគ្នា ឆាឬសាច់ចៀនស្ងួតដាក់ក្នុងចានដែកតូចជាងចានដែកមុនបន្តិច នឹងបង្អែមជាផ្លែឈើនឹងទឹកតែ, មុខម្ហូបទាំងនោះហៅថា "ម៉ឺនុយ-Menue" តែងតែមានបញ្ជាជាមុន១ខែ រៀបដោយប្រធានសិស្ស ឬសិស្សច្បង"ម៉ាស័រ-Major"ជាមួយនឹង"សែពគូស៊ីន"មានឋានជាសែ៊ហ្សង់ចូលរួមដោយក្រុមដំណាងសិស្សប្រមាណ១០-២០នាក់ផង។

ម្ហូបអាហារតែងចំអិននៅក្នុងរោងចំអិនជាមួយនឹងឆ្នាំងខ្ទះធំៗចំនួន៥-៦ ដោយពលទាហ៊ាន៦-៧នាក់ ក្រោមបញ្ជារបស់"សែពគូស៊ីន"នោះគេចូកម្ហូបដោយ"ប៉ែល"នឹងចង្វាធំៗ


រូបថតពេលបាយនៅសាលាកុមារយោធាដាឡាត់ ឆ្នាំ១៩៥០

រួមជាមួយវែកឆាដ៏ធំ កាន់ដោយនាយករបស់គេ សម្រាប់ភ្លក់គ្រប់ម្ហូបដែលកូនចៅកំពុងតែចំអិន យ៉ាងមមាញឹក គួរឱ្យចង់គយគន់ណាស់។ មែនហើយ កូនសិស្សជាច្រើនតែងតែមកគយគន់ ការធ្វើម្ហូប ដោយមានការបង្កាត់ភ្លើងដោយគល់អុសធំៗ ការឆារនឹងដាក់គ្រឿងញាប់ដៃដូចគេសម្តែងរបាំ ក្រោមផ្សែងនឹងក្លិនដ៏ឈ្ងុយឆ្ងាញ់ ហើយចេញមកយ៉ាងឆ្ងាយ ទាក់ទាញសិស្សកាន់តែច្រើនឱ្យចង់មកទស្សនា.... ម្លោះហើយលោកនាយកាន់"វែលឆា"ដ៏ធំនោះតែងតែដេញឱ្យសិស្សថយចេញទៅឆ្ងាយជារឿយៗ... ទាំងនេះបណ្តាយឱ្យសិស្សកត់សំគាល់"វែលឆា"ដ៏មានឫទ្ធិរបស់នាយឱ្យក្លាយទៅជាវត្ថុដ៏ល្បីល្បាញមួយ ដោយនៅពេលមុនលាគ្នានាឱកាសវិស្សមកាល គេបានបន្ទរនៅបទចម្រៀងរបស់នាង ម៉ៅ សារ៉េត មួយនៃវង្សដន្ត្រី"យោធាភិរម្យ" គឺនៅពេល

តទៅលេខក្រោយ

សមាគមបាល់ទាត់យុវជននៅឡូវែល

Lowell Youth Soccer Association

Spring Registration — ចុះឈ្មោះសម្រាប់រដូវផ្ការីក
Teams are available for — នៅសល់កន្លែងទំនេរ

Ages 3-11 Recreation League — អាយុ ៣-១១ឆ្នាំ ក្រុមហាត់ទាត់បាល់

9-14 Travel League - — អាយុ ៩-១៤ ឆ្នាំ ចាប់ផ្តើមប្រកួត

* Limited positions are available - Boys and Girls Under-10 - - Under-14
កំណត់កន្លែងដែលនៅសល់ -ក្មេងស្រី និងក្មេងប្រុសអាយុតិចជាង១០ឆ្នាំ -អាយុតិចជាង១៤ឆ្នាំ

Register On-line at:
lowellsoccer.com

តមកពីទំព័រទី ០៩

# ការអនុវត្តច្បាប់អន្តោប្រវេសន៏នាំមក...

មួយរដ្ឋាភិបាលសហរដ្ឋអាមេរិកក្នុងគោលបំណង ផ្តួលរំលំរបបរបស់គាត់ ។ រដ្ឋាភិបាលអាមេរិក បានឆ្លើយតមវិញជាមួយនឹងការដាក់ទណ្ឌកម្ម ដោយបញ្ឈប់ផ្តល់ទិដ្ឋាការដល់មន្ត្រីមួយចំនួនពីប្រទេសកម្ពុជា ។

ការដាក់ទណ្ឌកម្មនេះ បានធ្វើឱ្យក្រសួងការបរទេស និងសហប្រត្តិបការណ៍របស់ប្រទេសកម្ពុជា ចេញនូវរបាយការណ៏មួយកាលពីថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០១៧ ដោយបានលើកឡើងថា កម្ពុជាបានដាក់ស្នើការព្យួរជាបណ្តោះអាសន្ននៃ "ការធ្វើមាតុភូមិនិវត្ត ព្រមទាំងសេចក្តីបន្ថែមរបស់ខ្លួន" កាលពីខែតុលា ឆ្នាំ២០១៦ បន្ទាប់ពីមានការប្រឆាំងតវ៉ាដ៏ខ្លាំងក្លាពីសំណាក់សហគមន៏ខ្មែរអាមេរិកកាំង និងសមាជិកសភាអាមេរិកមួយចំនួន" ប៉ុន្តែឥឡូវនេះ មន្ត្រីកម្ពុជាបានសន្យាថា ខ្លួន "នឹងបន្តទទួលយកជនជាតិកម្ពុជាទាំងឡាយណាដែលត្រូវបាននិរទ្ទេសដោយសហរដ្ឋអាមេរិក" ។ ប៉ុន្មានខែបន្ទាប់មកទៀតភ្នាក់ងារ ICE បានចាប់ផ្តើមការឆ្មក់ចាប់ខ្លួនជាបន្តបន្ទាប់ក្នុងសហគមន៏ខ្មែរទូទាំងសហរដ្ឋអាមេរិក និងបានចាប់ខ្លួនមនុស្សជាច្រើននាក់ដែលក្នុងចំណោមពួកគេគឺមានកំណើតនៅក្នុងជំរុំជនភៀសខ្លួនដែលបានរត់គិចចេញពីរបបខ្មែរក្រហម ដែលជារបបសំលាប់ប្រជាជនខ្មែរច្រើនជាង២លាននាក់ក្នុងរង្វង់ឆ្នាំ១៩៧៥-១៩៧៩ ។



Nonprofits sue over immigration detention of Cambodian nationals who came as refu-gees

លោកមេធាវី ឃេវិន លូ (Kevin Lo) ដែលបំរើការនៅ Asian American Advancing Justice - Asian Law Caucus (ALC) បានមានប្រសាសន៏ថា "ទីភ្នាក់ងារ ICE ត្រូវបានតំរូវឱ្យផ្តល់នូវសេចក្តីជូនដំណឹងជាលាយលក្សអក្សរយ៉ាងហាចណាស់រយៈពេល ១៤ថ្ងៃមុននឹងឃាត់ខ្លួនពលរដ្ឋកម្ពុជា និងសេចក្តីបង្គាប់នេះ នឹងនៅបន្តសុពលភាពរហូតដល់ខែឧសភា ឆ្នាំ ២០១៩" ។ លោក លូ បាននិយាយតាមការសន្ទនាតាមទូរសព្ទ៍ជាមួយខ្មែរផុសថា "យើងបន្តធ្វើការជាមួយអង្គការ Southeast Asian ទូទាំងប្រទេសដើម្បីប្រឆាំងទៅនឹងការឆ្មក់ចាប់ខ្លួនរបស់ទីភ្នាក់ងារ ICE ដែលឥឡូវនេះបំពុងតែប៉ះពាល់ដល់សហគមន៏ខ្មែរជារាងរាល់៤ខែ ។ ហើយយើងដឹងថាមានកម្រោងរួមរាល់ហើយដែលពលរដ្ឋខ្មែរប្រហែលជា ២០០ នាក់នឹងត្រូវនិរទ្ទេសចេញពីប្រទេសមកកាន់ប្រទេសកំណើតជារាងជារៀងរាល់ឆ្នាំក្នុងរយៈពេលមួយទសវត្សរ៍ខាងមុខ" ។

ចាប់តាំងពីឆ្នាំ២០១៦មក អង្គការ Asian Americans Advancing Justice - Asian Law Caucus (ALC) តទៅទំព័រទី១៣

We make health care easy

Neighborhood has affordable plans for:
- Children and families
- Individuals
- Small businesses

យើងធ្វើឲ្យការថែទាំសុខភាពងាយស្រួល

Neighborhood មាន គម្រោងដែលមានតម្លៃសមរម្យសម្រាប់៖
- កុមារ និងក្រុមគ្រួសារ
- បុគ្គលម្នាក់ៗ
- អាជីវកម្មខ្នាតតូច

Neighborhood Health Plan OF RHODE ISLAND™

Contact us today to learn more!
សូមទាក់ទងមកយើងខ្ញុំនៅថ្ងៃនេះ ដើម្បីស្វែងយល់បន្ថែម!
www.nhpri.org

KhmerPost USA, LLC
សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក


អគ្គនាយក សុបិន្ទ ពិន
Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
sobenpin@khmerpost.us


និពន្ធនាយកខ្មែរ Khmer Editorial
និពន្ធនាយក ពិន សំខុន
Roger Samkhon Pin, Co-founder|Editor
(978-942-1641| rogerpin@khmerpost.us


Richard Howe Jr.
Contributed Writer | Editor

ផ្សាយពាណិជ្ជកម្ម សុបិន្ទ ពិន
Advertising Contact
Soben Pin
Cell: 979-656-8141
sobenpin@khmerpost.us

អ្នកនិពន្ធកិត្តិយស Staff Writer| Translator
Sokharath Koy

ច្នៃសោភ័ណ្ឌភាព Design Artist
Heng Chhun Leng

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.
Follow us: Facebook | Twitter KhmerpostUSA

តមកពីទំព័រទី ១២

## ការអនុវត្តច្បាប់អន្តោប្រវេសន៍នាំមក...

បានចូលរួមធ្វើការងារប្រឆាំងទៅនឹងការធ្វើនិរទេសពលរដ្ឋខ្មែរ។ លោក លូ និងសកហការីរបស់លោកត្រូវបានអញ្ជើញដោយអ្នករៀបចំនៅកម្ពុជាដើម្បីដំណើរការក្លីនិចស្របច្បាប់មួយសម្រាប់និរទេសជននៅក្នុងក្រុងភ្នំពេញ។ ពួកគេក៏បានចូលរួមក្រុមការងារពិសេសដែលរៀបចំដោយនាយករដ្ឋមន្ត្រីក្នុងការ ដោះស្រាយបញ្ហានៃការធ្វើនិរទេសពលរដ្ឋខ្មែរអាមេរិកកាំង។ និរទេសជនខ្មែរអាមេរិកកាំងបានផ្តល់សក្ខីកម្មចំពោះផលប៉ះពាល់នៃការធ្វើនិរទេសទៅលើសហគមន៍ និងគ្រួសាររបស់ពួកគេ។

លោកលូ បានបន្តថា "មានករណីជាច្រើនពួកគេអាចមានសិទ្ធក្នុងការត្រឡប់មកកាន់សហរដ្ឋអាមេរិកវិញ ប៉ុន្តែមិនមានប្រភពច្បាប់ក្នុងការជួយក្នុងការស្រាវជ្រាវជម្រើសនៃការត្រឡប់វិញនោះទេ"។

លោកលូ បានឆ្លើយតបតាមអ៊ីម៉ែលរបស់ខ្មែរផុសដោយបានសសេរថា "យើងបានបំពេញពាក្យបណ្តឹងរបស់លោក ឈឿន ហើយយើងបានចាប់ផ្តើមជួយពលរដ្ឋខ្មែរក្នុងការបើកសុំណំរឿងនៃសេចក្តីបង្គាប់បណ្តេញចេញចាប់របស់ពួកគេឡើងវិញចាប់តាំងពីច្បាប់ត្រូវបានផ្លាស់ប្តូរចំពោះការផ្តន្ទាទោសមនុស្សជាច្រើន។ នេះមានន័យថាពួកគេត្រូវបានគេឈប់ធ្វើនិរទេសទៀត ហើយតែចៅក្រមអន្តោប្រវេសន៍នៅតែចាំបាច់ត្រូវការការយល់ព្រមក្នុដើម្បីបើកសុំណំរឿងរបស់ពួកគេឡើងវិញ"។

ក្នុងឆ្នាំ ២០១៨ ពលរដ្ឋខ្មែរចំនួន១៣៦ នាក់ត្រូវបានចាប់ឃាត់ខ្លួន, ដាក់ពន្ធនាគារ ហើយបាននិរទ្ទេសមកកាន់ប្រទេសកម្ពុជាវិញ ជាបណ្តើរៗ ដោយមិនត្រូវទទួលបានការបើកការកាត់ក្តីសារជាថ្មីឡើងវិញនៅតុលាការនេះទេ ចំពោះសំណុំរឿងចាស់របស់ពួកគេ។




អង្គការ ALC បានជួយពលរដ្ឋខ្មែរពីរនាក់ដែលបាននិរទេសឱ្យមកកាន់អាមេរិកវិញដោយជោគជ័យ។ នាក់ទីមួយគឺលោក ទឹម ភ័ន បានត្រឡប់មកអាមេរិកវិញនៅខែ វិច្ឆិកា ឆ្នាំ ២០១៨។ លោក ភ័ន ត្រូវបាននិរទ្ទេសទៅកាន់ប្រទេសកម្ពុជានៅខែ មេសា ឆ្នាំ ២០១៨ និងលោក វ៉ាសនា ត្រូវបានខ្លាតឆ្ងាញពីគ្រួសាររបស់លោកតាំងពីឆ្នាំ២០១៤។

បើទោះបីជាករណីតុលាការនៅពុំទាន់សម្រេចយ៉ាងណាក្តី ក៏ការឆ្មក់ចាប់របស់ទីភ្នាក់ងារ ICE នឹងបន្តឡើងវិញនៅខែនេះ។ អង្គការ ALC បានចេញនូវការព្រមានជាមុនកាលពីថ្ងៃទី៥ ខែមិនា "ការឆ្មក់ចាប់លើកដំបូងរបស់ទីភ្នាក់ងារICE ដោយផ្តោតគោលពលរដ្ឋខ្មែរអាមេរិកកាំងក្នុងឆ្នាំ ២០១៩ បានចាប់ផ្តើមហើយកាលពីម្សិលមិញ" របាយការណ៍ក៏បានសសេរថា "យើងឈរនៅខាងសហគមន៍ជនភៀសខ្លួនខ្មែរ និងអំពាវនាវឱ្យមានការបញ្ចប់ការធ្វើនិរទេសដែលធ្វើឱ្យមានការភិតភ័យដល់ការរស់នៅរបស់ពលរដ្ឋអាស៊ីអាគ្នេយ៍។ យើងដឹងថា វាអាចទៅរួចក្នុងការប្រឆាំងទៅនឹងការធ្វើនិរទ្ទេស"។ អង្គការ ALC ជំរុញអ្នកទាំងអស់គ្នាមានទំនាក់ទំនងជាមួយទីភ្នាក់ងារ ICE ដោយទូរស័ព្ទទៅកាន់ helpline តាមរយៈលេខ 414-952-0413។

រាល់ពលរដ្ឋខ្មែរដែលមានសេចក្តីបង្គាប់បណ្តេញចេញចាស់គួរចាប់ផ្តើមប្រមូលឯកសារតុលាការអន្តោប្រវេសន៍ និងកំណត់ត្រាបទឧក្រិដ្ឋរបស់ខ្លួន។ធ្វើដូចច្នេះ មេធាវីអាចជួយពួកគេក្នុងការវាយតំលៃថា តើករណីរបស់ពួកគេអាចត្រូវបើកឡើវិញរឺយ៉ាងណា។ មានការការណែនាំតាមអនលាញដើម្បីជួយទទួលបាននូវកំណត់ត្រាទាំងនេះ និងប្រភពផ្សេងៗទៀតនៅលើវិបសាយ SEAraids.org។




មណ្ឌលពិនិត្យសុខភាពឡូវ៉ែល

Lowell Primary Care Center

លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.

Sokharith Mey, M.D. Chhan Touch, C.N.P.

LOWELL PRIMARY CARE CENTER LPCC មណ្ឌលពិនិត្យសុខភាពឡូវ៉ែល

ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

Now Accepting New Patients

ជំងឺទូទៅ សុខភាពផ្លូវចិត្ត

Family Medicine & Behavioral Health



អាស័យដ្ឋាន

1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992

ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត

បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances

Our Staff Speaks Khmer • Plenty of Free Parking

# SATHI'S SALON

ធ្វើសក់ - ក្រចក - ស្ប៉ា

HAIR - NAILS - SPA



295 Westford Street • Lowell, MA 01851

ជាប់រីងមុំ - ម៉ូដថ្មីៗ - លាបព័ណ - ប្តូរព័ណសក់ - អ៊ុតសក់ត្រង់

ផាត់មុខ និងធ្វើម៉ូតសក់សម្រាប់កម្មវិធីបញ្ចប់ការសិក្សារ និងមង្គល់ការ

FIRM - STYLE - COLOR - HIGHLIGHTS

PERMANENT STRAIGHTER

MAKE-UP & UPDO FOR PROM AND WEDDING

ស្វាគមន៍ភ្ញៀវអញ្ជើញមកដោយពុំមានការណាត់ជួប

WALK-INS WELCOME!

អាចធ្វើការណាត់ជាមុនតាមទូរស័ព្ទលេខ 978-7107035

Make Your Appointment 978-710-7035

ត្រូវការជ្រើសរើសជាងក្រចក និងបុគ្គលិកផ្នែកម៉ាស់សា!

ទូរស័ព្ទទៅកាន់ សាធី (Sathi) សម្រាប់ព័តមានលំអិត

យើងខ្ញុំប្រើប្រាស់ផលិតផលគុណភាពខ្ពស់សម្រាប់សក់!

Looking for Nail Technicians and Message Therapist! Call Sathi's for Details

We Use High Quality Products for Your Hair!


តមកពីទំព័រទី ០២

# សមាគមខ្មែរប្រូវីដិនត្រៀមខ្លួនធ្វើបុណ្យ

គណកម្មការរនាយកសមាគមខ្មែរ មាន លោក សម សុវណ្ណ លោក សំណាង បេគ័រ បាន ធ្វើការចាប់អារម្មណ៍ ចំពោះសារដែលខ្លួនត្រូវ ក្រើនរំលឹកប្រជាពលរដ្ឋខ្មែរនៅប្រូវិដិនជាច្រើន ដែលមិនបានប្រញាប់ប្រញាល់ទៅប្តូរយកអត្តសញ្ញាណប័ណ"ID"ថ្មីសោះ ព្រោះថា ID ចាស់នឹងត្រូវអស់សុពលភាព នៅថ្ងៃ ១តុលា២០២០ ខាងមុខនោះហើយ ដូច្នេះត្រូវទៅធ្វើអត្តសញ្ញាណប័ណ្ណថ្មី(Real ID) ដែលទាមទារដោយក្រសួង "Homeland Security" ដើម្បីជៀសវាង ការរំខាននៅពេលត្រូវចូលអាគិាសាធារណណាមួយ ឬក៏ដើម្បីធ្វើ"ដំណើរតាមជើងយន្តហោះក្នុងស្រុក"ជាដើម ។ ដើម្បីធ្វើ ID នោះគេត្រូវទៅ DMV នាំជាប់ទៅជាមួយ អត្តសញ្ញាណប័ណ្ណចាស់លិខិតបញ្ជាក់អស័យដ្ឋាន នឹងលិខិតឆ្លងដែន ដើម្បីឱ្យគេចេញ "អត្តសញ្ញាណប័ណ្ណ"ថ្មីនោះឱ្យសម្រាប់ប្រើប្រាស់ស្របច្បាប់ជាបន្តទៅទៀត ។

លោក សូផៃ មើយ សូមធ្វើការអំពាវនាវឱ្យបងប្អូនខ្មែរ មកចូលរួមបុណ្យចូលឆ្នាំ "វក" ឱ្យបានអ៊ឹកធឹកតាមកម្មវិធិះ

កម្មវិធីបុណ្យចូល ឆ្នាំ"កុរ"ព.ស.២៥៦៣

នៅថ្ងៃទី២០ ខែមេសា ២០១៩

ម៉ោង៨-១១ព្រឹកជួបជុំពុទ្ធបរិស័ទធ្វើកិច្ចនមស្សការព្រះរតនត្រ័យនិមន្តព្រះសង្ឃចំរើន ព្រះបរិត្ត បង្សុកូល - រាប់បាត - ប្រគេនចង្ហាន់ព្រះសង្ឃ

ម៉ោង១២ថ្ងៃ ការសម្តែងរបាំបូរាណខ្មែរ ដោយក្រុមសិល្បះសមាគមខ្មែរ



ក្រុមរបាំយុវជនរ៉ូដអាឡិន

១-៣រសៀល កម្មវិធីល្បែងប្រជាប្រិយ

៥កន្លះ ដល់១២អាធ្រាត រាំលេងកំសាន្តជាមួយ"ក្រុមតន្ត្រីពេជនិល"

នៅ Rhodes-on The Pawtukxet 60Rhode place, Cranston, RI 02905






# មណ្ឌលពិនិត្យសុខភាពលីន

## Lynn Primary Care Center

លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.

Sokharith Mey, M.D.

ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

Now Accepting New Patients

អាស័យដ្ឋាន

280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755

ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត

បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

LYNN PRIMARY CARE CENTER

មណ្ឌលពិនិត្យសុខភាពលីន

ជំងឺទូទៅ

*Family Medicine*

សុខភាពផ្លូវចិត្ត

*Behavioral Health*

We Accept MassHealth, Medicare and Other Health Insurances

Our Staff Speaks Khmer

## POSITION DESCRIPTION

| TITLE/DEPARTMENT | Maintenance Custodian |
|---|---|

**JOB SUMMARY**

The incumbent of this class performs routine building custodial and janitorial tasks. He/she maintains buildings and surrounding grounds in a lean and neat condition. Work is performed in accordance with standardized procedures or prior instructions.

**SUPERVISION RECEIVED**

The incumbent receives close guidance from the Property Manager. Work is reviewed while in progress and upon completion for accuracy and compliance with instructions.

**SUPERVSION GIVEN**

The incumbent does not give supervision to others.

**KNOWLEDGE, SKILLS, and ABILITIES**

1. Knowledge of methods and practices used in janitorial or custodial work
2. Knowledge of proper use of a variety of special cleaning and sanitizing solutions and solvents.
3. Ability to read signs and follow oral and written instructions.
4. Ability to move heavy furniture, supplies and equipment.
5. Ability to use common cleaning tools and equipment.
6. Ability to perform building custodial tasks under supervision.
7. Ability to operate lawn care and snow removal equipment.
8. Knowledge of basic maintenance of buildings.
9. Shall possess a valid Driver's License.

**PRINCIPAL DUTIES**

1. Cleans and polishes floors located in storerooms, corridors, elevators, stairwells lavatories and other areas by" sweeping, mopping, scrubbing, waxing, and polishing, using a variety of hand implements and equipment, such as: brooms, mops, vacuum cleaners, floor scrubbers, floor buffers, etc.
2. Keeps rest rooms clean by sweeping, scrubbing and waxing floors: disinfects and deodorizes lavatories, urinals and toilet bowls: washes sinks mirrors and fountains: maintain in a clean and sanitary condition.
3. Maintains grounds by selecting the proper tools, implements or equipment to perform a variety of tasks, such as pruning shrubs and trees, reseeding bare spots in lawns spraying insecticide on shrubs and trees, removing snow and ice.
4. Custodians shall perform emergency repairs as needed.
5. Performs routine custodial and janitorial tasks, such as: emptying waste baskets, washing windows, emptying trash compactors, lifting containers and carrying them out of building, vacuuming rugs and carpets, stripping wax from floors, and similar tasks.
6. Applies appropriate solvents and solutions, such as detergents, soaps, scouring powders, waxes, polishes, etc.
7. Performs a number of routine security functions, such as: Checking to make certain that designated offices and buildings are secured at specific times of the day/night.
8. Cleans and paints vacant apartments by washing walls, ceilings, windows floors, cupboards, lavatories and by steam cleaning appliances.
9. Perform other related duties of the class, as required.

**TRAINING/EXPERIENCE**

The nature of this work does not require any prior training or experience. A candidate should be in good physical condition, and should be able to demonstrate the ability to understand oral and written instructions. Some manual dexterity is called for. Good physical condition is essential.

| Approved by Board of Commissioners: | Date: REVISED 2.26.15 |
|---|---|

KhmerPost USA

The **KhmerPost USA** is the premier **free** biweekly newspaper for Khmer and English readers. We committed to the best news and information to our readers and advertisers that we have provided for the past 10 years to the Cambodian communities in New England.

Currently reaching 50,000 readers every month
Distribution outlets include:

- Local Markets and Convenience Stores
- Restaurants, Retail Stores, and Chambers of Commerce
- Government Offices and Office Buildings
- Cleaners and Laundromats
- Buddhist Temples and much more

**For Advertising Opportunities**
**Contact:** 978.677.7163
Web: www.khmerpostusa.com

Celebrating 10 Years of Service

PROGRAM FOR Asian American Student Advancement AT MIDDLESEX COMMUNITY COLLEGE

CHAB DAI

**THE BUTTERFLY LONGITUDINAL RESEARCH PROJECT**

*A presentation on re-integration for male and female survivors of sex trafficking in Cambodia.*

**Thursday, March 28, 2019**
**11am - 12:30pm**
Lowell Campus, Federal Building, Assembly Room

*featuring*

**Vanntheary Lim**
Project Manager

**Channtha ThNhanh**
Assistant Project Manager





For more information contact Linda Thiem at THIEML@middlesex.mass.edu or call 978-656-3447.

MIDDLESEX Community College This film screening supports the Multicultural & Global Literacy and Social Responsibility Institutional Student Learning Outcomes.


VICHET CHUM
JOEL COLODNER
TINA FABRIQUE
CAROLINE NEFF
RAVIV ULLMAN
JACK KEROUAC
THE HAUNTED LIFE
MAR 20 - APR 14
$10 LOWELL NIGHT MARCH 28
MRT.ORG FOR DETAILS
BY SEAN DANIELS
BASED ON THE BOOK BY JACK KEROUAC
DIRECTED BY SEAN DANIELS
AND christopher oscar peña
If you follow your heart, where will it lead you?
TWO WAYS TO SAVE!
ANNIVERSARY SPECIAL
2 FOR $40
Use promo code HAPPYPOST
Select seats, strictly limited availability. Details at mrt.org/hauntedlife.
CELEBRATION SPECIAL
SAVE $10
Use promo code CELEBRATEPOST
Applies to regular-priced seats. Details at mrt.org/hauntedlife.
MERRIMACK REPERTORY THEATRE
MRT
circlehealth
SEASON SPONSOR
Enterprise Bank
PRODUCTION SPONSOR
90.9 wbur
MEDIA SPONSOR
merrimack valley